# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៣៤ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ និងមាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួននៃអនុក្រឹត្យលេខ២៣អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

## សម្រេច

www.pheakdeylaw.com

មាត្រាមួយ.-

ត្រូវបានកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ និងមាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួន នៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចតទៅ ៖

មាត្រា ៤ថ្មី.-

លេខាធិការដ្ឋាន គ.ជ.អ.ប មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- សហការ សម្របសម្រួលសិក្សាអំពីចក្ខុវិស័យសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយផ្សារភ្ជាប់ជាមួយគោលនយោបាយកំណែទម្រង់នានា ដើម្បីសុំការអនុម័តពី គ.ជ.អ.ប
- អភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត ដើម្បីគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រៀបចំឱ្យមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ដើម្បីសុំការសម្រេចពី គ.ជ.អ.ប
- គាំទ្រ សម្របសម្រួលការអនុវត្តកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ព្រមទាំងរៀបចំ និងអនុវត្តនូវប្រព័ន្ធតាមដាន និងវាយតម្លៃក្នុងកម្រិតកម្មវិធីជាទូទៅលើផែនការ និងកម្មវិធីទាំងនោះ ក្នុងនាម គ.ជ.អ.ប
- សិក្សា និងលើកយោបល់សុំការសម្រេចពី គ.ជ.អ.ប ក្នុងការកែសម្រួលកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ និងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ ផ្អែកលើវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- សហការរៀបចំឱ្យមានការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាអំពីការពិនិត្យមើលឡើងវិញនូវមុខងារ និងការផ្ទេរមុខងារ និងធនធានទៅតាមដំណាក់កាលនានា ដែលកំណត់ដោយ គ.ជ.អ.ប
- បំពេញតួនាទីជាលេខាធិការដ្ឋានឱ្យអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប
- សម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់ គ.ជ.អ.ប ស្របតាមគោលការណ៍ណែនាំនានារបស់ គ.ជ.អ.ប
- ធ្វើការពិនិត្យ សង្ខេប បូកសរុបឯកសារ របាយការណ៍លទ្ធផលនៃកិច្ចប្រជុំ អនុសាសន៍ សំណើសំណូមពរ ដែលផ្តល់ជូនដោយអនុគណៈកម្មាធិការនានា ដោយភ្ជាប់ជាមួយអនុសាសន៍របស់ខ្លួនដើម្បីដាក់ជូនប្រធាន គ.ជ.អ.ប ពិនិត្យ សម្រេច
- ត្រៀមរៀបចំកិច្ចប្រជុំទាំងអស់របស់ គ.ជ.អ.ប
- សម្របសម្រួល និងរៀបចំឱ្យមានការពិគ្រោះយោបល់នានានៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា ក្នុងដំណើរការនៃការអនុវត្តកំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ព្រមទាំងលិខិតបទដ្ឋានអនុវត្តច្បាប់ទាំងនេះ ស្របតាម


www.pheakdeylaw.com

ការណែនាំរបស់ គ.ជ.អ.ប

- សម្របសម្រួលគម្រោងគាំទ្រពីដៃគូអភិវឌ្ឍន៍នានាដល់ដំណើរការកំណែទម្រង់ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមការណែនាំពី គ.ជ.អ.ប
- អាចធ្វើជាប្រតិបត្តិករនូវគម្រោង កម្មវិធីដែលគាំទ្រពីដៃគូអភិវឌ្ឍន៍នានា តាមការសម្របសម្រួលគ្នារវាងដៃគូអភិវឌ្ឍន៍ទាំងនោះ និងតាមការសម្រេចរបស់ គ.ជ.អ.ប
- ចូលរួមជាមួយដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសវិមជ្ឈការ និងវិសហមជ្ឈការ
- គ្រប់គ្រងថវិកា និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប
- បំពេញការងារផ្សេងៗទៀតតាមការកំណត់របស់ គ.ជ.អ.ប ។

មាត្រា ៧ថ្មី.-

លេខាធិការដ្ឋាន គ.ជ.អ.ប មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ
- អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន
- អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី
- អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ
- ក្រុមសវនកម្មផ្ទៃក្នុង
- ក្រុមជំនួយការ។

អង្គភាពនីមួយៗត្រូវដឹកនាំដោយប្រធាន០១រូប មានឋានៈស្មើនឹងអគ្គនាយករង និងអនុប្រធានមួយចំនួន មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ដែលតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.អ.ប។

អង្គភាពនីមួយៗត្រូវមានការិយាល័យចំណុះមួយចំនួន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប។ ការិយាល័យចំណុះនីមួយៗ ត្រូវមានប្រធាន០១រូប មានឋានៈស្មើនឹងប្រធានការិយាល័យនៅថ្នាក់កណ្តាល និងអនុប្រធានមួយចំនួន មានឋានៈស្មើនឹងអនុប្រធានការិយាល័យនៅថ្នាក់កណ្តាល ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

ក្រុមសវនកម្មផ្ទៃក្នុង មានប្រធាន០១រូប មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ដែលតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.អ.ប និងអនុប្រធាន០១រូប មានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

ក្រុមជំនួយការ មានប្រធាន០១រូប មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ដែលតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន គ.ជ.អ.ប និងអនុប្រធាន០២រូប មានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន ដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប តាមសំណើរបស់ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

**អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ** មានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- សិក្សាស្រាវជ្រាវ វិភាគ រៀបចំ និងតម្រឹមក្របខ័ណ្ឌគតិយុត្តនានាសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចជា ការផ្ទេរមុខងារនិងធនធាន វិមជ្ឈការហិរញ្ញវត្ថុ ការកសាងផែនការ ការគ្រប់គ្រងបុគ្គលិក ការគ្រប់គ្រងធនធានធម្មជាតិ ការបញ្ជ្រាបយេនឌ័រ ការប្រែប្រួល



www.pheakdeylaw.com

អាកាសធាតុ និងការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- សម្របសម្រួលជាមួយអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានាសម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តនានាដើម្បីគាំទ្រកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន** មានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំ និងអនុវត្តក្របខ័ណ្ឌត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំ និងការអនុវត្តក្របខ័ណ្ឌគតិយុត្តសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ
- រៀបចំរបាយការណ៍ស្តីពីការអនុវត្តកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ និងគម្រោង កម្មវិធីនានា
- ប្រមូល ចងក្រង និងផ្សព្វផ្សាយទិន្នន័យ ព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**អង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធី** មានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំ គាំទ្រ និងអនុវត្តកម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ
- កៀរគរធនធានសម្រាប់ការអនុវត្តកម្មវិធីជាតិ ផែនការអនុវត្តកម្មវិធីជាតិ ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប
- សម្របសម្រួល និងតម្រឹមគម្រោង កម្មវិធីដោយឡែកនានាជាមួយកម្មវិធីជាតិ។

**អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ** មានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- គ្រប់គ្រង ចាត់ចែង និងផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការអនុវត្តកម្មវិធីជាតិ និងផែនការអនុវត្តកម្មវិធីជាតិ
- គ្រប់គ្រងបុគ្គលិក ទីប្រឹក្សាជាតិ អន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យា ដែលចុះកិច្ចសន្យាបំពេញការងារដោយ គ.ជ.អ.ប
- ចាត់ចែង និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់ គ.ជ.អ.ប។

**ក្រុមសវនកម្មផ្ទៃក្នុង** មានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ធ្វើសវនកម្មផ្ទៃក្នុងលើការអនុវត្តរបស់អង្គភាពទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលទទួលអនុវត្តកម្មវិធី ឬគម្រោងស្ថិតនៅក្រោមក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ គ.ជ.អ.ប
- រៀបចំរបាយការណ៍សវនកម្ម ដោយផ្តល់អនុសាសន៍ដែលមានភស្តុតាង និងមូលហេតុសមស្របជូនប្រធានលេខាធិការដ្ឋាន ដើម្បីចាត់វិធានការសមស្រប
- តាមដានលើការអនុវត្តអនុសាសន៍ និងត្រួតពិនិត្យមើលវិធានការនានាដែលបានអនុវត្ត ដើម្បីឆ្លើយតបទៅតាមអនុសាសន៍ទាំងនោះ
- សម្របសម្រួល និងសហការជិតស្និទ្ធជាមួយបេសកកម្មសវនកម្មឯករាជ្យ សវនកម្ម និងឬអធិការកិច្ចរបស់រាជរដ្ឋាភិបាល។

**ក្រុមជំនួយការលេខាធិការដ្ឋាន គ.ជ.អ.ប** មានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- សម្របសម្រួល សហការ និងធ្វើទំនាក់ទំនងជាប្រចាំជាមួយអង្គភាព និងការិយាល័យនានានៃលេខាធិការដ្ឋាន គ.ជ.អ.ប



www.pheakdeylaw.com

- សហការរៀបចំរបៀបវារៈ និងខ្លឹមសារសម្រាប់កិច្ចប្រជុំ គ.ជ.អ.ប និងរក្សាទុកជាក់ឯកសារប្រជុំទាំងអស់របស់ គ.ជ.អ.ប
- ពិនិត្យ និងផ្តល់យោបល់លើឯកសារ និងរបាយការណ៍នានាដែលត្រូវដាក់ជូនថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យ សម្រេច
- រៀបចំឯកសារ របាយការណ៍ និងកំណត់ហេតុកិច្ចប្រជុំនានារបស់ថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប
- រៀបចំកាលវិភាគ និងការណាត់ជួបពិភាក្សាការងារនានារបស់ថ្នាក់ដឹកនាំលេខាធិការដ្ឋាន គ.ជ.អ.ប។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធលម្អិតរបស់អង្គភាព ក្រុមសវនកម្មផ្ទៃក្នុង និងក្រុមជំនួយការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប។

**មាត្រា ៩ថ្មី.-**

អនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប ប្រធាន អនុប្រធាន មន្ត្រីរាជការស៊ីវិលតាមអង្គភាពនានា ក្រុមសវនកម្មផ្ទៃក្នុង និងក្រុមជំនួយការនៃលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ និងមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ននានា ដែលមានចំណេះដឹង និងមានបទពិសោធន៍ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

មន្ត្រីរាជការស៊ីវិលដែលបានជ្រើសរើស និងតែងតាំងឱ្យបំពេញការងារក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបំពេញការងារពេញម៉ោងក្នុងលេខាធិការដ្ឋាន លើកលែងតែប្រធាន និងអនុប្រធានទី១នៃលេខាធិការដ្ឋាន គ.ជ.អ.ប។

ក្រសួង ស្ថាប័នសាមីត្រូវអនុញ្ញាតឲ្យមន្ត្រីរាជការស៊ីវិល ដែលបានតែងតាំងទាំងនោះមកបំពេញការងារពេញម៉ោងក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប។

មន្ត្រីរាជការស៊ីវិលដែលបានជ្រើសរើស និងតែងតាំងក្នុងមុខតំណែងនានា ក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប ដូចមានចែងក្នុងមាត្រា៧ថ្មីនៃអនុក្រឹត្យនេះ ត្រូវទទួលបាននូវប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗ នៅក្រសួង ស្ថាប័នដើមរបស់ខ្លួន។ ក្រសួង ស្ថាប័នសាមីត្រូវរៀបចំប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់មន្ត្រីរាជការស៊ីវិលដែលបានតែងតាំងទាំងនោះ ទៅតាមនីតិវិធី និងគោលការណ៍ដែលបានកំណត់។

ក្នុងករណីដែលមន្ត្រីរាជការស៊ីវិលស្ម័គ្រចិត្តមកបម្រើការងារក្នុងមុខតំណែង ដែលបានជ្រើសរើស និងតែងតាំងក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប ប៉ុន្តែមុខតំណែងនោះមានឋានៈទាបជាងមុខតំណែងនៅក្រសួង ស្ថាប័នដើម សាមីខ្លួនមានសិទ្ធិទទួលបានប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់ឧបត្ថម្ភផ្សេងៗក្នុងមុខតំណែងនៅក្រសួង ស្ថាប័នដើម។

ក្នុងរយៈពេលបំពេញការងារក្នុងរចនាសម្ព័ន្ធលេខាធិការដ្ឋាន គ.ជ.អ.ប មន្ត្រីរាជការស៊ីវិលទាំងនោះ មានសិទ្ធិត្រូវបានដំឡើងឋានន្តរស័ក្តិ ថ្នាក់ និងកម្រិតប្រាក់បំណាច់មុខងារ ព្រមទាំងត្រូវបានរក្សាទុកនូវអតីតភាពការងារសម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១២ថ្មី.-**

លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវសហការសម្របសម្រួលជាមួយអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានាដែលជាសមាជិកនៃ គ.ជ.អ.ប ដើម្បីគាំទ្រដល់កិច្ចដំណើរការប្រចាំថ្ងៃរបស់



www.pheakdeylaw.com

លេខាធិការដ្ឋាន។

គ.ជ.អ.ប អាចកំណត់ដោយសេចក្តីសម្រេចបន្ថែមទៀតនូវកិច្ចសហការសម្របសម្រួល និងទំនាក់ទំនងការងាររវាងក្រសួង ស្ថាប័នខាងលើនេះ។

**មាត្រា១២ស្ទួន.-**

លេខាធិការដ្ឋាន គ.ជ.អ.ប មានសិទ្ធិប្រើប្រាស់សញ្ញាសម្គាល់ និងត្រារបស់ គ.ជ.អ.ប ដូចបានចែងនៅក្នុងមាត្រា១១នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា ១៥ថ្មី.-**

ប្រធានអង្គភាពនីមួយៗត្រូវមានការទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះអនុប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប ដែលបានចាត់ឱ្យទទួលខុសត្រូវលើអង្គភាពនោះ ព្រមទាំងមានការទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប។

**មាត្រា ១៧ថ្មី.-**

ក្នុងពេលមិនទាន់បានរៀបចំលេខាធិការដ្ឋាន គ.ជ.អ.ប ស្របតាមគោលការណ៍នៃអនុក្រឹត្យដែលបានកែសម្រួលនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ដែលមាននាពេលបច្ចុប្បន្ននេះ ត្រូវធ្វើជាលេខាធិការដ្ឋានបណ្តោះអាសន្ននៃ គ.ជ.អ.ប។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

ប្រធាន គ.ជ.អ.ប រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**<u>កន្លែងទទួល</u>** ÷

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រាបី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com